# NAPLAN ព័ត៌មានសម្រាប់ មាតាបិតានិងអ្នកថែទាំ 2024

## ហេតុអ្វីបានជាសិស្សានុសិស្សធ្វើតេស្ត NAPLAN?

កម្មវិធីវាយតម្លៃថ្នាក់ជាតិ - ការចេះអាននិង ចេះសរសេរ និងលេខនព្វន្ត (NAPLAN) គឺជា ការវាយតម្លៃលើការចេះអាននិងចេះសរសេរ និងលេខនព្វន្តដែលសិស្សរៀននៅថ្នាក់ទី 3, 5, 7 និង្ថនាក់ទី 9 រៀននៅក្នុងឆ្នាំសិក្សានីមួយៗ។ វាជាការវាយតម្លៃថ្នាក់ជាតិតែមួយគត់ដែលគ្រប់សិស្សអូស្ត្រាលីទាំងអស់មានឱកាសធ្វើ។

នៅពេលសិស្សានុសិស្សមានការវិវត្តន៍នៅក្នុងឆ្នាំសិក្សានៅសាលារៀនរបស់ពួកគេ ជាការសំខាន់ ត្រូវពិនិត្យមើលថាពួកគេកំពុងរៀនសូត្រលើជំនាញសំខាន់ៗក្នុងការអាន ការសរសេរ និង លេខនព្វន្តយ៉ាងណាដែរ។

NAPLAN វាយតម្លៃលើជំនាញក្នុងការចេះអាន និងចេះសរសេរ និងលេខនព្វន្ត ដែល សិស្សានុសិស្សកំពុងរៀនសូត្រតាមរយៈកម្មវិធីសិក្សានៅសាលា និងអនុញ្ញាតឱ្យ ឪពុកម្តាយ/អ្នកថែទាំ មើលឃើញថាកូន របស់ពួកគេកំពុងមានវឌ្ឍនភាពយ៉ាងណាដែរ បើប្រៀបធៀបទៅនឹងស្តង់ដារភាពស្ទាត់ជំនាញថ្នាក់ជាតិ។

NAPLAN គឺគ្រាន់តែជាផ្នែកមួយនៃ ការវាយតម្លៃនិងការរាយការណ៍របស់សាលា ប៉ុណ្ណោះ។ វាមិនដាក់ជំនួសលើការវាយតម្លៃកំពុងបន្តមានដែលបានធ្វើឡើងដោយគ្រូបង្រៀនអំពីប្រសិទ្ធផលរបស់សិស្សនោះទេ ប៉ុន្តែវាអាចផ្តល់ឱ្យ គ្រូបង្រៀននូវព័ត៌មានបន្ថែមអំពីវឌ្ឍនភាពផ្នែកអប់រំរបស់សិស្សានុសិស្ស។

NAPLAN ក៏ផ្តល់ទៅសាលា អាជ្ញាធរសិក្សាធិការ និងរដ្ឋាភិបាលនូវព័ត៌មានអំពីថាតើកម្មវិធី សិក្សាដំណើរការយ៉ាងដូចម្តេច ហើយនិងថា តើយុវជនអូស្ត្រាលីទទួលបានសមិទ្ធិផលសំខាន់ៗក្នុងវិស័យអាននិងសរសេរ និងវិស័យគិតលេខឬអត់។

## កូនរបស់អ្នកនឹងធ្វើតេស្ត NAPLAN តាមអនឡាញ

តេស្ត NAPLAN តាមអនឡាញត្រូវបាន រៀបចំរចនាឡើងដើម្បីផ្តល់លទ្ធផលជាក់លាក់ និងមានការចូលរួមរបស់សិស្សានុសិស្ស។ តេស្តត្រូវបានធ្វើឱ្យត្រូវតាមបុគ្គល (ឬមានការបត់បែន) ដែលមានន័យថា តេស្ត នីមួយៗបង្ហាញនូវសំណួរនានាដែលអាចពិបាកជាងមុន ឬមិនពិបាកជាងមុន អាស្រ័យលើ ចម្លើយរបស់សិស្ស។ ការធ្វើដូចនេះជួយឱ្យសិស្សានុសិស្សនៅតែចូលរួមពាក់ព័ន្ធជាមួយនឹងការវាយតម្លៃ។

ការធ្វើតេស្តដែលអាចមានការបត់បែនតាម សិស្សម្នាក់ៗបាន គឺអនុញ្ញាតឲ្យការវាយតម្លៃនោះ អាចវាយតម្លៃសមត្ថភាពចម្រុះកាន់តែច្រើនរបស់សិស្ស ហើយការវាស់វែងសមិទ្ធិផល របស់សិស្សក៏កាន់តែមានភាពសុក្រឹត។ លទ្ធផល NAPLAN សរុបរបស់សិស្សម្នាក់ គឺអាស្រ័យលើទាំងចំនួននិងទាំងភាពស្មុគ្រស្មាញរបស់សំនួរដែលសិស្សនោះឆ្លើយត្រូវ។ កូនរបស់អ្នកមិនគួរបារម្ភទេប្រសិនបើគាត់ឃើញសំនួរទាំងឡាយពិបាកឆ្លើយ ព្រោះគាត់អាច ជ្រើសយកផ្លូវដែលមានភាពស្មុគ្រស្មាញជាងអ្នកផ្សេង។

សិស្សឆ្នាំទី៣គ្រប់ទាំងអស់នឹងបន្តធ្វើតេស្តតាមការសរសេរលើក្រដាស។

## តើ NAPLAN វាយតម្លៃអ្វី?

NAPLAN វាយតម្លៃចំណេះដឹងខាងអាន និង សរសេរនិងខាងគិតលេខរបស់សិស្សដែលរៀន តាមកម្មវិធីសិក្សារបស់សាលាជាធម្មតា។

សិស្សធ្វើការប្រឡងសរសេរ អាន ក្បួនច្បាប់ របស់ភាសា(ការប្រកបពាក្យ វេយ្យាករណ៍ និងការប្រើវណ្ណយុត្ត) និងការគិតលេខ។ សំណួរទាំងនោះវាយតម្លៃចំណេះដឹងដែលផ្សារភ្ជាប់ទៅនិងកម្មវិធីសិក្សាអូស្ត្រាលី ៖ ភាសាអង់គ្លេសនិងគណិតវិទ្យា។

គ្រប់អាជ្ញាធរក្នុងវិស័យសិក្សាធិការ ក្នុងនិងក្រៅរដ្ឋាភិបាល សុទ្ធតែរួមចំណែក ក្នុងការបង្កើតវិញ្ញាសារនៃតេស្ត NAPLAN ។

ដើម្បីយល់បន្ថែមទៀតអំពី NAPLAN សូមចូលទៅ nap.edu.au

## ការចូលរួមក្នុង NAPLAN

NAPLAN គឺសម្រាប់សិស្សថ្នាក់ទី 3, 5, 7 និងសិស្សថ្នាក់ទី 9។ ACARA គាំទ្រដល់ការធ្វើតេស្តដែលមាន លក្ខណៈរួមបញ្ចូល ដើម្បីឱ្យសិស្សានុសិស្ស ទាំងអស់មានឱកាសចូលរួមក្នុងកម្មវិធីតម្លៃ ថ្នាក់ជាតិ។

ការកែតាមតម្រូវការអាចធ្វើបានសម្រាប់សិស្សដែលមានពិការភាពដែលមានសម្ថភាពនិង សេចក្តីត្រូវការខុសៗគ្នាក្នុងការធ្វើកិច្ចការប្រចាំកាយ។

សាលាទាំងឡាយគួរធ្វើការជាមួយមាតាបិតា/អ្នកថែទាំ ហើយនិងសិស្សដើម្បីដឹងក្នុងករណីនិមួយៗ នូវការកែតម្រូវសមរម្យដែលសិស្សដែលមានពិការភាពត្រូវការ ដើម្បីចូលរួមក្នុងកម្មវិធី NAPLAN ។ ការកែតម្រូវទាំងឡាយគួរស៊ីគ្នាជាមួយនិងជំនួយដែលធម្មតាមានផ្តល់ឲ្យនៅពេលធ្វើការវាយតម្លៃក្នុងថ្នាក់។

ដើម្បីជួយក្នុងការផ្តល់ព័ត៌មានអំពីការសម្រេចទាំងនេះ អ្នកអាចចូលមើល កន្លែងបង្ហាញសកម្មភាពគំរូជាសាធារណៈរបស់ NAPLAN សេចក្តីណែនាំសម្រាប់សាលា ដើម្បីជួយសិស្សដែលមានពិការភាព ក្នុងការចូលរួមក្នុងកម្មវិធី NAPLAN ឬក៏កម្រងវីដេអូ របស់យើងស្តីអំពីមាតាបិតា/អ្នកថែទាំ គ្រូ និងសិស្សដែល ចែករំលែកបទពិសោធរបស់ពួកគេក្នុងការប្រើ NAPLAN ដែលមានការកែតម្រូវតាមតម្រូវការ។

ក្នុងករណីពិសេស សិស្សដែលមានពិការភាព ដែលធ្វើឲ្យសមត្ថភាពគេមានកំរិតទាបខ្លាំងក្នុងការចូលរួមក្នុងកម្មវិធីវាយតម្លៃនេះ ឬសិស្សដែលទើបនិងមកប្រទេសអូស្ត្រាលីថ្មីៗ ហើយមកពីប្រទេសដែលមិននិយាយភាសាអង់គ្លេស អាចត្រូវបានផ្តល់ការលើកលែងជាផ្លូវការ។

នាយកសាលារបស់អ្នក ឬអាជ្ញាធរចាត់ចែង ការធ្វើតេស្តក្នុងតំបន់របស់អ្នក អាចផ្តល់ជូន អ្នកនូវព័ត៌មានបន្ថែមស្តីអំពីការកែតម្រូវសម្រាប់សិស្សដែលមានពិការភាព ឬក៏នីតិវិធីដែល ត្រូវធ្វើដើម្បីទទួលបានការលើកលែងជាផ្លូវការ។



Translation © VCAA

## តើខ្ញុំអាចធ្វើអ្វីដើម្បីជួយកូនខ្ញុំ?

គេមិននឹកថាសិស្សត្រូវរៀនដើម្បីធ្វើតេស្ត NAPLAN ទេ។ អ្នកអាចជួយកូនអ្នកដោយធ្វើឲ្យកូនទុកចិត្តថាការធ្វើតេស្ត NAPLAN គឺជាផ្នែកមួយនៃ កម្មវិធីរបស់សាលា ហើយរំលឹកកូនថាគ្រាន់តែ សុំធ្វើឲ្យអស់ពីសមត្ថភាពទៅ។ ការពន្យល់ខ្លះៗអំពី NAPLAN មានប្រយោជន៍ ក្នុងការជួយដល់សិស្សឱ្យយល់ និងមានអារម្មណ៍ ស្រណុកស្រួលជាមួយនឹងទម្រង់នៃការតេស្ត យ៉ាងណាក៏ដោយវាមិនចាំបាច់សម្រាប់ឪពុក ម្ដាយ/អ្នកថែទាំធ្វើដូចនេះទេ។ គ្រូនឹងធ្វើយ៉ាងណាឲ្យសិស្សដឹងអំពីប្រភេទនៃសំនួរនៅក្នុងតេស្ត ហើយផ្ដល់ការគាំទ្រសមស្រប ហើយនិងការណែនាំ។

អាជ្ញាធរ ACARA មិនស្នើឲ្យធ្វើការរៀបចំ ត្រៀមខ្លួនច្រើនហួសហេតុឡើយសម្រាប់ការធ្វើតេស្ត NAPLAN ឬក៏ប្រើអង្គភាពផ្ដល់សេវា បង្ហាត់បង្រៀនផ្សេងៗឡើយ។

សូមមើលប្រភេទនៃសំណួរ និងឧបករណ៍នានា ដែលមាននៅក្នុងការវាយតម្លៃ NAPLAN តាមអនឡាញនៅឯ NAP - គេហទំព័របង្ហាញជាសាធារណៈ។

## តើគេនឹងធ្វើរាយការណ៍អំពីការធ្វើបានរបស់កូនខ្ញុំដោយវិធីណា?

ចាប់ពីឆ្នាំ 2023 មក លទ្ធផល NAPLAN ត្រូវបានរាយការណ៍ប្រៀធៀបជាមួយនឹង ស្តង់ដារភាពស្ទាត់ជំនាញ។ មានស្តងដារមួយ សម្រាប់ផ្នែកនៃការវាយតម្លៃនីមួយៗ នៅកម្រិត ឆ្នាំនីមួយៗ។ ស្តតង់ដារភាពស្ទាត់ជំនាញផ្ដល់នូវព័ត៌មានច្បាស់លាស់លើសមិទ្ធផលសិស្ស។ ស្តងដារទាំងនោះ កំណត់ពីការប្រឈម ប៉ុន្តែកម្រិតសមហេតុផល ដែលបានរំពឹងទុកសម្រាប់កុមារនៅឯពេលវេលានៃការធ្វើតេស្ត NAPLAN ផ្អែកសំខាន់លើអ្វីដែល បានបង្រៀននៅឆ្នាំមុនៗនៃការរៀននៅសាលា។ សមិទ្ធផលរបស់សិស្សត្រូវបានបង្ហាញដោយប្រៀបធៀបនឹង 4 កម្រិតនៃភាពស្ទាត់ជំនាញ៖ លើសលប់ ខ្លាំង កំពុងវិវត្ត និងត្រូវការ ការគាំទ្របន្ថែម។

របាយកាណ៍ NAPLAN ផ្ទាល់ខ្លួនរបស់សិស្សនិមួយៗ នឹងត្រូវបានផ្ដល់ដោ យសាលារបស់កូនអ្នកនៅពេលក្រោយទៀតនៅក្នុងឆ្នាំនេះ។ ប្រសិនបើអ្នកមិនបានទទួលរបាយណ៍ អ្នកគួរតែទាក់ទងទៅសាលារបស់កូនអ្នក។

## ចុះបើកូនរបស់ខ្ញុំអវត្តមានពីសាលានៅថ្ងៃធ្វើតេស្ត NAPLAN វិញយ៉ាងម៉េចដែរ?

ក្នុងករណីដែលអាចធ្វើបាន សាលាអាច ចាត់ចែងឲ្យសិស្សនិមួយៗ ដែលបានអវត្តមាននៅពេលធ្វើតេស្ត ឲ្យធ្វើតេស្តដែលខ្លួន បានខកខាននៅពេលមួយទៀតក្នុង សប្ដាហ៍នៃការធ្វើតេស្តនោះ។

## តើគេប្រើលទ្ធផល NAPLAN របៀបដូចម្ដេច?

- សិស្សនិងមាតាបិតា/អ្នកថែទាំ អាចប្រើលទ្ធផលផ្ទាល់ខ្លួនដើម្បីពិគ្រោះអំពីការលូតលាស់ជាមួយគ្រូ។
- គ្រូប្រើលទ្ធផលដើម្បីជួយក្នុងការសំគាល់សិស្សដែលត្រូវការចំណោទកាន់តែពិបាក ឬក៏ត្រូវការជំនួយបន្ថែម។
- សាលាប្រើលទ្ធផលដើម្បីសំគាល់ចំណុចខ្លាំងនិងផ្នែកនានាដែលត្រូវការជំនួយ ដើម្បីកែលំអកម្មវិធីបង្រៀន ហើយនិងកំណត់គោលដៅក្នុងវិស័យអាននិងសរសេរ និងវិស័យគិតលេខ។
- ប្រព័ន្ធសាលាប្រើលទ្ធផលដើម្បីពិនិត្យឡើងវិញនូវប្រសិទ្ធិភាពនៃកម្មវិធីនិង ជំនួយដែលសាលាបានទទួល។
- សហគមន៍អាចមើលព័ត៌មានអំពីការធ្វើបានរបស់សាលានាពេលមុននិងពេលក្រោយនៅ myschool.edu.au

## តើខ្ញុំអាចរកព័ត៌មានបន្ថែមទៀតនៅទីណា?

សម្រាប់ព័ត៌មានបន្ថែមអំពី NAPLAN ៖

- សូមទាក់ទងជាមួយសាលារបស់កូនអ្នក
- សូមទាក់ទងជាមួយអាជ្ញាធរចាត់ចែងការធ្វើតេស្តនៅមូលដ្ឋានរបស់អ្នកនៅ nap.edu.au/TAA
- សូមចូលទៅ nap.edu.au

ដើម្បីយល់ដឹងថា តើ ACARA ចាត់ចែងយ៉ាងណាខ្លះចំពោះព័ត៌មានផ្ទាល់ខ្លួនសម្រាប់ NAPLAN សូមចូលទៅ nap.edu.au/naplan/privacy

## កាលវិភាគរបស់ NAPLAN

កំឡុងពេលនៃការធ្វើតេស្ត NAPLAN មានរយៈពេល ៩ ថ្ងៃ។ ការនេះនឹងផ្ដល់ដល់សាលានានាដែលអាចមិនមានសមត្ថភាពក្នុងការរៀបចំបំពេញការធ្វើតេស្តក្នុងរយៈពេលខ្លី។

វីនដូធ្វើតេស្ត NAPLAN ចាប់ផ្ដើមនៅថ្ងៃពុធ ទី 13 ខែមីនា និងបញ្ចប់នៅថ្ងៃចន្ទ ទី 25 ខែមីនា ឆ្នាំ 2024។ សាលារៀននានានឹងកំណត់កាលវិភាគធ្វើតេស្តឱ្យបានលឿនដែលអាចធ្វើទៅបាន នៅក្នុង វីដូធ្វើតេស្ត ដោយកំណត់អាទិភាព សប្ដាហ៍ទីមួយ។

| តេស្ត | តម្រូវការក្នុងការធ្វើកាលវិភាគ | កំឡុងពេល | ការរៀបរាប់អំពីតេស្ត |
|---|---|---|---|
| ការសរសេរ | • សិស្សឆ្នាំទី៣ ធ្វើតេស្តសរសេរលើក្រដាស (តែថ្ងៃទី១ ប៉ុណ្ណោះ)<br>• វិញ្ញាសារសរសេររបស់ថ្នាក់ឆ្នាំទី៥ ទី៧ និង ទី៩ ត្រូវតែចាប់ផ្ដើមនៅថ្ងៃទី១ (សាលាត្រូវតែចាត់ជាអាទិភាពឲ្យវិញ្ញាសារសរសេរធ្វើឲ្យហើយរវាងតែថ្ងៃទី១ និង ទី២ ប៉ុណ្ណោះ ដោយថ្ងៃទី២ប្រើសម្រាប់តែករណីដែលមានកង្វះខាតផ្នែកបច្ចេកទេស/ដឹកជញ្ជូនប៉ុណ្ណោះ) | ឆ្នាំទី៣ : ៤០ នាទី<br>ឆ្នាំទី៥ : ៤២ នាទី<br>ឆ្នាំទី៧ : ៤២ នាទី<br>ឆ្នាំទី៩ : ៤២ នាទី | សិស្សានុសិស្សត្រូវបានផ្ដល់ឱ្យនូវគំនិត ឬ ប្រធានបទមួយដែលហៅថា “គ្រឿងជំរុញ លើកទឹកចិត្តក្នុងការសរសេរ” ឬ “សារតម្រុយ” ហើយត្រូវបានស្នើឱ្យសរសេរចម្លើយមួយនៅក្នុងប្រភេទជាក់លាក់មួយ (ការសរសេររៀបរាប់ ឬបញ្ចុះបញ្ចូល) |
| ការអាន | • ត្រូវធ្វើបន្ទាប់ពីធ្វើតេស្តសរសេរហើយ | ឆ្នាំទី៣ : ៤៥ នាទី<br>ឆ្នាំទី៥ : ៥០ នាទី<br>ឆ្នាំទី៧ : ៦៥ នាទី<br>ឆ្នាំទី៩ : ៦៥ នាទី | សិស្សអានអត្ថបទនានាដែលមានព័ត៌មានផ្សេងៗ មានលក្ខណៈស្រមើស្រមៃ និងមានលក្ខណៈ បញ្ចុះបញ្ចូល ហើយបន្ទាប់មកឆ្លើយសំណួរ ដែលពាក់ព័ន្ធ |
| ក្បួនច្បាប់ភាសា | • ត្រូវធ្វើក្រោយធ្វើតេស្តអាន | ឆ្នាំទី៣ : ៤៥ នាទី<br>ឆ្នាំទី៥ : ៤៥ នាទី<br>ឆ្នាំទី៧ : ៤៥ នាទី<br>ឆ្នាំទី៩ : ៤៥ នាទី | សិស្សត្រូវបានវាយតម្លៃលើការប្រកបពាក្យ វេយ្យាករណ៍ និងវណ្ណយុត្តិ |
| ចំណេះដឹងខាងគិតលេខ | • ត្រូវធ្វើក្រោយធ្វើតេស្តអំពីក្បួនច្បាប់ភាសា | ឆ្នាំទី៣ : ៤៥ នាទី<br>ឆ្នាំទី៥ : ៥០ នាទី<br>ឆ្នាំទី៧ : ៦៥ នាទី<br>ឆ្នាំទី៩ : ៦៥ នាទី | សិស្សត្រូវបានវាយតម្លៃលេខនិងពិជគណិត រង្វាស់រង្វាល់ និងធរណីមាត្រ និងស្ថិតិនិងប្រូបាប៊ីលីតេ |



Translation © VCAA